# ការហូរឈាមបន្ទាប់ពីដកធ្មេញ

ការហូរឈាមកើតដោយសារជាលិកាអញ្ចាញ និង ជាលិកាជុំវិញធ្មេញបានរងប៉ះខូចខាត ។ បរិមាណនៃការហូរឈាមអាចកើតដោយសារ :

Local Factor :

- ទំហំនៃការខូចខាតបង្កដោយ Elevator រឺ ដង្កាប់ដកធ្មេញ
- បរិមាណនៃការរលាកជាលិកាជុំវិញធ្មេញទាំងរយៈពេលខ្លីផ្ទី១ និង ជំងឺជុំវិញធ្មេញ រឺ អញ្ចាញមានលក្ខណៈយូរ (នឹងមានឈាមមកផ្គត់ផ្គង់ កន្លែងមានជាលិកាហើម និង បុសខ្ទុះ ច្រើន) ។ ប្រសិនបើពួកគេមានឈាមអញ្ចាញដោយសារខ្វះការដុសធ្មេញ ប្រសិនបើមានធ្មេញរង្គើដោយសារជម្ងឺជាលិកាជុំវិញធ្មេញនឹងមានហូរឈាមច្រើនពីរណ្តៅក្រោយដកធ្មេញ ។ ប្រសិនបើធ្មេញធំជាមួយ រឹសវែងដែលបង្កឱ្យរហែកអញ្ចាញច្រើននៅពេលដកធ្មេញ ។

Medical Factor

អ្នកជំងឺប្រហែលមានបញ្ហាឈាមហូរព្រោះជម្ងឺមហារីកគ្រាប់ឈាមស ជម្ងឺថ្លើម ជម្ងឺឈាមក្រកក និង សំពាធឈាមខ្ពស់(លើសឈាម) ព្រោះតែការប្រើប្រាស់ថ្នាំធ្វើឱ្យឈាមអត់សូវខាប់(ថ្នាំប្រឆាំងកំនកឈាម) រឺ អាស្ពីរីន ការហូរឈាមអាចបន្ថយដោយប្រើថ្នាំស្ពឹកទៅលើធ្មេញព្រោះក្នុងថ្នាំស្ពឹកមានVasocontrictor (ធ្វើឱ្យសសៃឈាមរួម) ដោយបន្ថយលំហូរឈាម ដូចជាពពួក Adrenaline និង Epineprine ។

អ្នកជំងឺអាចត្រូវផ្តល់Chlorohexidene Gluconateទំរង់ជាទឹកសំរាប់សំអាតមាត់ រឺ gel ពីរបីថ្ងៃក្រោយមុនដកធ្មេញដើម្បីកាត់បន្ថយចំនួនបាកតេរី និង កាត់បន្ថយការរលាកផ្សេងៗ ។

The Clotting System(ប្រពន្ធ័កំនកឈាម)

នៅពេលសសៃឈាមត្រូវបានប៉ះពាល់ខូចខាតវានឹងធ្វើឱ្យសសៃឈាមកាន់តែតូច បន្ទាប់មកវាបញ្ចេញកត្តាកកឈាមដែលនឹងបង្កplateletនៅក្នុងឈាមទៅតោងភ្ជាប់កន្លែងដែលប៉ះពាល់ ហើយធ្វើឱ្យសសៃប្រូតេអ៊ុនបង្កើតទៅជាកំនក ។

After an Extraction(បន្ទាប់ពីដកធ្មេញ)



ជំរើសល្អដើម្បីបញ្ឈប់ឈាមហូរ និង ជួយឱ្យជាសះគឺត្រូវប្រើកំលាំងសង្កត់ទៅលើរណ្តៅដើម្បីបញ្ឈប់ឈាមហូរ និង ជំរុញឱ្យមានកំនកឈាម ។ អ្នកជំងឺត្រូវខាំដុំស្បៃដែលមានល្បេប វ៉ាសេលីន ដែលដាក់លើរណ្តៅយ៉ាងខ្លាំង យ៉ាងហោចណាស់ ១០ ទៅ ១៥ នាទី ។

កន្លែងដកនោះមិនត្រូវប៉ះពាល់វា ដើម្បីកុំឱ្យដាច់កំនកឈាមដែលផុយងាយដាច់ ។ ដុំស្បៃដែលមានលៀប វ៉ាសេលីន ដ៏ល្អឥតខ្ចោះគឺត្រូវប៉ុនរណ្តៅធ្មេញ (ទំហំត្រូវប៉ុនរណ្តៅធ្មេញ ហើយខ្ពស់ជាងធ្មេញដែលនៅក្បែរ ដើម្បីអោយធ្មេញទល់មុខ ខាំប៉ះណែនល្អ ) ។ វាត្រូវហាប់ណែនល្មមដើម្បីសង្កត់លើរណ្តៅ(សំលីដែលមូលមិន បានល្អ មិនគួរប្រើទេ ពីព្រោះ វាមិនហាប់ល្អ ក្នុងការបញ្ជូនកំលាំងសង្កត់ទៅលើរណ្តៅ) ។

ដុំសំលីគួរពាសដោយVaselineជុំវិញ កុំឱ្យវាមានឈាមជាប់ជ្រៅទៅក្នុងដុំស្បៃ ម៉្យាងទៀត បើមិនមានVaseline កំណកឈាម អាចដាច់មកជាមួយដុំសំលី ។ ដុំស្បៃដ៏ល្អ មិនត្រូវអោយធំជាង ដុំសំលីមូលស្រាប់ឡើយ ។ ដាក់ Vaselineខ្លះលើស្បៃខាងក្រៅ ដាក់ដុំសំលីមូល១ រឺ ២នៅលើស្បៃ ហើយមូលវាឱ្យតឹងជាមួយស្បៃ បន្ទាប់មកដាក់ Vaselineឱ្យច្រើនលើផ្ទៃស្បៃទាំងមូល ។



ជំនួយការពេទ្យគួរប្រាកដថាមាត់អ្នកជំងឺត្រូវស្អាតគ្មានកំទេចកំទី គ្មានឈាម និង គ្មានទឹកមាត់ នៅក្នុងមាត់ មុនពេលដាក់ដុំស្បៃនោះ លើរណ្តៅ ដើម្បីអោយអ្នកជំងឺមានផាសុខភាព និង មិនចងស្តោះ រឺ ខ្ពុរមាត់ ។ ជូតសំអាតឈាម ជុំវិញមាត់អ្នកជំងឺ និង បបូរមាត់ចេញ ជាមួយសំលីសើម និង សំអួតអោយស្អាតល្អ ។ បន្ទាប់ពី អ្នកជំងឺបានខាំដុំស្បៃដែលមានលៀប វ៉ាសេលីន ១០ទៅ ១៥ នាទី ជំនួយការពេទ្យរឺ គ្រូពេទ្យត្រូវយកដុំសំលីចេញ ហើយពិនិត្យមើល ថាតើ នៅមានឈាមហូរ រឺ អត់ មុនពេលឱ្យលំណែនាំចុងក្រោយដល់អ្នកជម្ងឺ មុនឱ្យគាត់ទៅផ្ទះគាត់វិញ ។

## លំណែនាំទៅអ្នកជម្ងឺក្រោយដកធ្មេញ

- មិនឱ្យខ្ពុរមាត់ មិនឱ្យលាងមាត់ រឺ ខាកស្តោះចេញ រយៈពេល ៤ ម៉ោងបន្ទាប់ពីដកធ្មេញ
- កុំពិសារម្ហូបក្តៅ រឺ ផឹកក្តៅ រយៈពេល ៤ ម៉ោងបន្ទាប់ពីដកធ្មេញ
- មិនត្រូវហាត់ប្រាណខ្លាំងពេក មិនត្រូវផឹកស្រា មិនត្រូវជក់បារី ឡើយ
- កុំប៉ះកន្លែងដកនោះដោយអណ្តាត រឺ ដៃ ឱ្យសោះ
- ប្រើ ថ្នាំបំបាត់ការឈឺចាប់ បន្ទាប់ពីជាតិថ្នាំស្ពឹកអស់ ព្រោះវាអាចមានការឈឺចាប់

ប្រសិនបើឈាមនៅតែហូរមិនឈប់ រឺ នៅតែឈឺលើសពី ២ ថ្ងៃ សូមទាក់ទងមកគ្លីនិកព្យាបាល ។ វាប្រសើរណាស់ ដែលសសេរការណែនាំទៅឱ្យអ្នកជម្ងឺក៏ដូចជានិយាយប្រាប់គាត់ ។ ហើយដុំស្បៃបន្ថែម អាចផ្តល់អោយអ្នកជំងឺ បើសិនជា យើងគិតថា អាចនៅមានការហូរឈាមទៀត ។ បញ្ហា ដែលអាចកើតក្រោយពីដកធ្មេញរួមមាន : ហើម ជាំ ជាប់គាំង ការហូរឈាម និង ឈឺ ......:

**ការហើម** អាចកើតដោយសាររលាកជាលិកាជុំវិញធ្មេញ វាកំរកើតលើការដកធម្មតា ។ ការហើមអាចកាត់បន្ថយទៅវិញដោយយើងគ្រាន់តែស្អំទឹកកកនៅលើថ្ពាល់ ត្រង់កន្លែងហើម បន្ទាប់ពីដកធ្មេញ រឺ វះកាត់ ។

**ភាពជាំ** គឺជាលទ្ធផលនៃលំហូរឈាមទៅជាលិកាជុំវិញរណ្តៅធ្មេញ តែវាមិនសូវមានទេ លើការដកធ្មេញធម្មតា និង មនុស្សវ័យជំទង់ ប៉ុន្តែ វាកើតមានជាញឹកញាប់ ជាមួយការដកធ្មេញថ្គាមទាល់ខាងក្រោមពិបាក។ វាមិនមានការឈឺចាប់អ្វីទាំងអស់ ហើយ មួយអាទិត្យក្រោយមក វានឹងបាត់ទៅវិញ ។

**ភាពជាប់គាំង** គឺការរឹងសាច់ដុំ នៅពេលអ្នកជំងឺព្យាយាមហាមាត់ វាកើតដោយសារការចាក់ថ្នាំស្ពឹក IDB ប្រើនៅក្នុងការដកធ្មេញថ្គាមខាងក្រោម ហើយវាធ្វើឱ្យខូចខាត និង ហើមសាច់ដុំ ។

**ការហូរឈាម** បើនៅតែហូរឈាម ២ រឺ ៣ ម៉ោង បន្ទាប់ពីដកធ្មេញ ជាទូទៅ នេះជា លទ្ធផលនៃ ការមិនមានកំនកឈាមល្អ នៅលើអញ្ចាញដែលរលាក ហើយនិង លំហូរឈាមចេញមកមិនឈប់ ។



អ្នកជម្ងឺអាចមានដុំកំនកឈាមធំៗ ជាច្រើនក្នុងមាត់របស់គាត់ ។ មាត់អ្នកជម្ងឺគួរតែសំអាតថ្នមៗដោយស្បៃសើម ហើយអោយអ្នកជំងឺ ខាំដុំស្បៃមានវ៉ាសេលីន ១៥ នាទីទៀត ។ ប្រសិនបើឈាមនៅតែហូរយើងត្រូវចាក់ថ្នាំស្ពឹក ដើម្បីកាត់បន្ថយការ ហូរឈាម ហើយដាក់ Gelatine Sponge, Surgicel or Fibrin Foam ក្នុងរណ្តៅដើម្បីជំនួយដល់កំនកឈាម ។ បន្ទាប់មកយើងទាញអញ្ចាញនៅលើរណ្តៅ ចូលគ្នារួចដេរខ្ទប់មាត់ រណ្តៅ ។

**ការឈឺចាប់ អាចកើតមានឡើង**២ រឺ ៣ ម៉ោងក្រោយពីថ្នាំស្ពឹកអស់ប្រសិទ្ធភាព ហើយអាចបន្តនៅជាច្រើនថ្ងៃ ។ ជាទូទៅ ការឈឺចាប់នេះ បណ្តាលមកពី Dry Socket ។ វាកើតនៅពេលអត់មានកំនកឈាមនៅក្នុងរណ្តៅ ហើយឆ្អឹងនៅក្នុងរណ្តៅបានប៉ះផ្ទាល់ទៅនឹងខ្យល់ ហើយវាធ្វើអោយមានការឈឺចាប់ខ្លាំងក្លា ។ ពេលខ្លះធ្មេញនៅជាប់នឹងរណ្តៅក៏ឈឺដែរ ។




រណ្តៅធ្មេញគួរតែលាងជំរះដោយSaline រឺ Chlorohexidine និង បិទបំពេញជាមួយ Antiseptic ដូចជា Alvogyl ។ ការដាក់ Zinc Oxide Eugenol ជាមួយសំលីបន្ទិច ចូលក្នុងរណ្តៅធ្មេញអាចជួយសំបកឆ្អឹងជាសះស្បើយ ។ Dry Socket ត្រូវការយ៉ាងហោចណាស់រយ:ពេល ១ ទៅ ២ សប្តាហ៍ ហើយត្រូវការសំអាត និង ដាក់ថ្នាំ ២ រឺ ៣ ដង ដើម្បីអោយជាសះស្បើយវិញ ។